ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦ ស.ស.ក.ប.ក

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី

សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដោយបានឆ្លងកាត់កិច្ចប្រជុំពិនិត្យនិងពិភាក្សាយ៉ាងល្អិតល្អន់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ស្របតាមច្បាប់ជាតិនៃភាគីនីមួយៗ និងតាមច្បាប់អន្តរជាតិ ដែលកិច្ចប្រជុំទាំងនេះបានប្រព្រឹត្តទៅលើកទី១ នៅថ្ងៃទី៣០ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ នៅរដ្ឋធានីមូស្គូនៃសហព័ន្ធរុស្ស៊ី និងលើកទី២ នៅថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។ ភាគីទាំងពីរបានឯកភាពគ្នា និងបានចុះហត្ថលេខាជាផ្លូវការលើសន្ធិសញ្ញានេះនៅរាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។

សន្ធិសញ្ញានេះ មានគោលបំណងពង្រឹងមូលដ្ឋានច្បាប់នៃការផ្តល់ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ដោយឈរលើគោលការណ៍គោរពនូវអធិបតេយ្យភាព សមភាព សុចរិតភាពដែនដី មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់បទឧក្រិដ្ឋកម្មឆ្លងដែន រួមមាន ការជួញដូរមនុស្សពិសេសស្ត្រីនិងកុមារ អំពើពុករលួយ ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម និងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាអាទិ៍ ដោយអនុលោមតាមច្បាប់ជាតិរបស់គូភាគីនិងគោរពគោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់។

សន្ធិសញ្ញានេះផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍ដល់គូភាគីក្នុងការបង្កើតឱ្យមានក្របខ័ណ្ឌគតិយុត្តសម្រាប់ព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ីក្នុងការធ្វើសំណើនិងអនុវត្តសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីជួយដល់ការស៊ើបអង្កេតនិងនីតិវិធីតុលាការរបស់ភាគីនីមួយៗ។

សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី មាន២៤មាត្រា ដែលមានខ្លឹមសារសង្ខេបសំខាន់ៗដូចខាងក្រោម៖

- មាត្រា១ កំណត់អំពីវិសាលភាពនៃជំនួយផ្នែកច្បាប់
- មាត្រា២ កំណត់អំពីកាតព្វកិច្ចក្នុងការផ្តល់ជំនួយផ្នែកច្បាប់
- មាត្រា៣ កំណត់អំពីអាជ្ញាធរកណ្តាល
- មាត្រា៤ កំណត់អំពីទម្រង់និងខ្លឹមសារនៃសំណើ
- មាត្រា៥ កំណត់អំពីភាសា
- មាត្រា៦ កំណត់អំពីការបដិសេធឬការពន្យាពេលឆ្លើយតបចំពោះសំណើ
- មាត្រា៧ កំណត់អំពីសុពលភាពនៃឯកសារ
- មាត្រា៨ កំណត់អំពីការសម្ងាត់និងភាពមានកម្រិតនៃការប្រើប្រាស់ព័ត៌មាន
- មាត្រា៩ កំណត់អំពីការអនុវត្តសំណើ
- មាត្រា១០ កំណត់អំពីសេវាកម្មឯកសារ
- មាត្រា១១ កំណត់អំពីការយកភស្តុតាង
- មាត្រា១២ កំណត់អំពីការផ្តល់ព័ត៌មាន ឯកសារ និងកំណត់ហេតុ
- មាត្រា១៣ កំណត់អំពីការឆែកឆេរនិងការដកហូត
- មាត្រា១៤ កំណត់អំពីទីតាំងនិងអត្តសញ្ញាណរបស់មនុស្សនិងវត្ថុ
- មាត្រា១៥ កំណត់អំពីការបង្ហាញខ្លួនដោយផ្ទាល់របស់សាក្សី ជនរងគ្រោះ និងអ្នកឯកទេសនៅក្នុងទឹកដីរបស់ភាគីធ្វើសំណើ
- មាត្រា១៦ កំណត់អំពីសុវត្ថិភាព
- មាត្រា១៧ កំណត់អំពីការផ្ទេរជាបណ្តោះអាសន្នចំពោះបុគ្គលដែលកំពុងជាប់ឃុំ(រាប់បញ្ចូលបុគ្គលទាំងឡាយណាដែលកំពុងទទួលទោសក្នុងទម្រង់ជាការជាប់ពន្ធនាគារ)
- មាត្រា១៨ កំណត់អំពីការដោះដូរព័ត៌មានអំពីការផ្តន្ទាទោសនិងកំណត់ហេតុតុលាការ
- មាត្រា១៩ កំណត់អំពីកិច្ចការពារបុគ្គលដែលចូលបង្ហាញខ្លួនតាមការស្នើសុំឬត្រូវបានផ្ទេរទៅទឹកដីរបស់ភាគីទទួលសំណើ
- មាត្រា២០ កំណត់អំពីករណីពិសេសនៃការផ្តល់ជំនួយផ្នែកច្បាប់
- មាត្រា២១ កំណត់អំពីផលនៃបទល្មើសនិងមធ្យោបាយប្រព្រឹត្តបទល្មើស
- មាត្រា២២ កំណត់អំពីការចំណាយ
- មាត្រា២៣ កំណត់អំពីការពិគ្រោះយោបល់និងការដោះស្រាយវិវាទ
- មាត្រា២៤ កំណត់អំពីអវសានប្បញ្ញត្តិ។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន២មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់នេះដោយក្តីអនុគ្រោះ។

ថ្ងៃ សុក្រ ១០ រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**